ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងប្រៀបធៀបបទប្បញ្ញត្តិ
# នៃក្រមរដ្ឋប្បវេណីដែលបានវិសោធនកម្ម
# ដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

បោះពុម្ពផ្សាយ
២០២១

| ក្រមរដ្ឋប្បវេណី ២០០៧ | ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ២០១១ |
|---|---|
| **មាត្រា១២១ សមាសភាគនៃវត្ថុ**<br><br>ចំពោះសមាសភាគនៃវត្ថុអ្វីមួយ ដែលមិនអាចបែងចែកបានដោយមិនបំបែកវត្ថុនោះ ឬ ដោយមិនផ្លាស់ប្តូរ*លក្ខណៈដើមនៃសមាសភាគនោះ*ទេ ភាគនៃវត្ថុនោះមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបានឡើយ។ | **មាត្រា១២១ សមាសភាគនៃវត្ថុ**<br><br>ចំពោះសមាសភាគនៃវត្ថុអ្វីមួយ ដែលមិនអាចបែងចែកបានដោយមិនបំបែកវត្ថុនោះ ឬ ដោយមិនផ្លាស់ប្តូរលក្ខណៈដើមនៃវត្ថុនោះទេ ភាគនៃវត្ថុនោះមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបានឡើយ។ |
| **មាត្រា ១៣៨ និយមន័យនៃកម្មសិទ្ធិ**<br><br>កម្មសិទ្ធិ សំដៅទៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធរបស់ខ្លួន ដោយសេរីបាន នៅ*ក្នុងទំហំដែលច្បាប់បានកម្រ*។ | **មាត្រា ១៣៨ និយមន័យនៃកម្មសិទ្ធិ**<br><br>កម្មសិទ្ធិ សំដៅទៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធរបស់ខ្លួន ដោយសេរីបាន នៅក្នុងទំហំដែលច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀតបានកម្រិត។ |
| **មាត្រា ១៨៥ កម្មសិទ្ធនៃបាតទន្លេ ឬ ស្ទឹងចាស់ដោយសារការបង្កើតផ្លូវទឹកថ្មី( វាក្យខណ្ឌទី ៣ និង ទី ៤)**<br><br>នៅពេលទន្លេ ស្ទឹង ឬ ព្រែកដែលនាវា ឬ ក្បូនអាចចេញចូលបាន បណ្តែតបាន បង្កើតផ្លូវទឹកថ្មី ដោយបោះបង់ចោល ផ្លូវទឹកចាស់ កម្មសិទ្ធិករនៃដីជាប់មាត់ច្រាំងនោះអាចធ្វើលទ្ធកម្មកម្មសិទ្ធិនៃបាតទន្លេ ស្ទឹង ឬ ព្រែកចាស់ ហើយទំហំនៃកម្មសិទ្ធិលើដីគោករបស់ម្នាក់ៗ ត្រូវមានរហូតដល់ខ្សែបន្ទាត់កណ្តាលនៃទន្លេ ស្ទឹង ឬ ព្រែកនោះ។ កម្មសិទ្ធិករនៃដីជាប់មាត់ច្រាំងនោះ ត្រូវបង់តម្លៃដែលត្រូវបានកំណត់ដោយអ្នកវាយតម្លៃ។ តម្លៃនៃបាតទន្លេ ស្ទឹង ឬ ព្រែកចាស់ត្រូវបានកំណត់ដោយអ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការដែលមានសមត្ថកិច្ចលើទីកន្លែងនោះ តាមពាក្យសុំរបស់*អាជ្ញាធរខេត្ត-ក្រុង* ឬ អ្នកដែលមានពាក់ព័ន្ធផលប្រយោជន៍។ ប៉ុន្តែ ក្នុងករណីដែលកម្មសិទ្ធិករនៃដីជាប់មាត់ច្រាំងនោះ មិនបង្ហាញឆន្ទៈយកកម្មសិទ្ធិលើបាតទន្លេ ស្ទឹង ឬ ព្រែកចាស់នោះទេ ដីគោកនោះ ត្រូវបានលក់ជាសាធារណៈដោយ*អាជ្ញាធរខេត្ត-ក្រុង*។ ប្រាក់ដែលកម្មសិទ្ធិករនៃដីជាប់មាត់ច្រាំងបានបង់ ឬ ប្រាក់ដែលបានទទួលពីការលក់បាតទន្លេ ស្ទឹង ឬ ព្រែកចាស់នោះ ត្រូវបែងចែកឲ្យកម្មសិទ្ធិករដែលបាន | **មាត្រា ១៨៥ កម្មសិទ្ធនៃបាតទន្លេ ឬ ស្ទឹងចាស់ដោយសារការបង្កើតផ្លូវទឹកថ្មី( វាក្យខណ្ឌទី ៣ និង ទី ៤)**<br><br>នៅពេលទន្លេ ស្ទឹង ឬ ព្រែកដែលនាវា ឬ ក្បូនអាចចេញចូលបាន បណ្តែតបាន បង្កើតផ្លូវទឹកថ្មី ដោយបោះបង់ចោល ផ្លូវទឹកចាស់ កម្មសិទ្ធិករនៃដីជាប់មាត់ច្រាំងនោះអាចធ្វើលទ្ធកម្មកម្មសិទ្ធិនៃបាតទន្លេ ស្ទឹង ឬ ព្រែកចាស់ ហើយទំហំនៃកម្មសិទ្ធិលើដីគោករបស់ម្នាក់ៗ ត្រូវមានរហូតដល់ខ្សែបន្ទាត់កណ្តាលនៃទន្លេ ស្ទឹង ឬ ព្រែកនោះ។ កម្មសិទ្ធិករនៃដីជាប់មាត់ច្រាំងនោះ ត្រូវបង់តម្លៃដែលត្រូវបានកំណត់ដោយអ្នកវាយតម្លៃ។ តម្លៃនៃបាតទន្លេ ស្ទឹង ឬ ព្រែកចាស់ត្រូវបានកំណត់ដោយអ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការដែលមានសមត្ថកិច្ចលើទីកន្លែងនោះ តាមពាក្យសុំរបស់អាជ្ញាធររាជធានី ខេត្ត ឬ អ្នកដែលមានពាក់ព័ន្ធផលប្រយោជន៍។ ប៉ុន្តែ ក្នុងករណីដែលកម្មសិទ្ធិករនៃដីជាប់មាត់ច្រាំងនោះ មិនបង្ហាញឆន្ទៈយកកម្មសិទ្ធិលើបាតទន្លេ ស្ទឹង ឬ ព្រែកចាស់នោះទេ ដីគោកនោះត្រូវបានលក់ជាសាធារណៈដោយអាជ្ញាធររាជធានី ខេត្ត។ ប្រាក់ដែលកម្មសិទ្ធិករនៃដីជាប់មាត់ច្រាំងបានបង់ ឬ ប្រាក់ដែលបានទទួលពីការលក់បាតទន្លេ ស្ទឹង ឬ ព្រែកចាស់នោះ |

| | |
|---|---|
| បាត់បង់ដីដោយសារ ការបង្កើតផ្លូវទឹកថ្មី តាមសមាមាត្រនៃតម្លៃដីដែលបានបាត់បង់ដោយសារទឹកហូរ។ | ត្រូវបែងចែកឲ្យកម្មសិទ្ធិករដែលបានបាត់បង់ដីដោយសារ ការបង្កើតផ្លូវទឹកថ្មី តាមសមាមាត្រនៃតម្លៃដីដែលបានបាត់បង់ដោយសារទឹកហូរ។ |
| **មាត្រា ២៣៣ ការកាន់កាប់ដោយមានវិការៈ (កថាខណ្ឌទី ១ វាក្យខណ្ឌទី ១)** | **មាត្រា ២៣៣ ការកាន់កាប់ដោយមានវិការៈ (កថាខណ្ឌទី ១ វាក្យខណ្ឌទី ១)** |
| ១- ការកាន់កាប់*ដោយបានដឹងថាខ្លួនគ្មានសិទ្ធិកាន់កាប់ទេ* ហៅថា ការកាន់កាប់ដោយទុច្ចរិត រីឯការកាន់កាប់*ដោយមិនបានដឹងថាខ្លួនគ្មានសិទ្ធិទេ* ហៅថា ការកាន់កាប់ដោយសុចរិត។ ករណីដែលមានកំហុសក្នុងការមិនបានដឹងនោះ ហៅថា ការកាន់កាប់ដោយមានកំហុស។<br><br>២~៤-.......... | ១- ការកាន់កាប់ដោយបានដឹងថាខ្លួនគ្មានសិទ្ធិអំណាចក្នុងការកាន់កាប់ទេ ហៅថា ការកាន់កាប់ដោយទុច្ចរិត រីឯការកាន់កាប់ដោយមិនបានដឹងថាខ្លួនគ្មានសិទ្ធិអំណាចទេ ហៅថា ការកាន់កាប់ដោយសុចរិត។ ករណីដែលមានកំហុសក្នុងការមិនបានដឹងនោះ ហៅថា ការកាន់កាប់ដោយមានកំហុស។<br>២~៤-.......... |
| **មាត្រា ២៤២ ការការពារភោគីអចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ (កថាខណ្ឌទី ១ និង ទី ៣)** | **មាត្រា ២៤២ ការការពារភោគីអចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ (កថាខណ្ឌទី ១ និង ទី ៣)** |
| ១- ភោគីដែលប្រើប្រាស់ និងអាស្រ័យផលជាបន្តនូវអចលនវត្ថុដែលបានទទួល*ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ* តែមិនទាន់ចុះបញ្ជីអចលនវត្ថុដែលជាការចាំបាច់ដើម្បីទទួលកម្មសិទ្ធិពេញលេញ ដោយសារមិនទាន់បានរៀបចំប្រព័ន្ធប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីទេ ត្រូវចាត់ទុកថាជាកម្មសិទ្ធិករ ចំពោះការអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស។<br><br>២-..........<br><br>៣- អ្នកដែលបានទទួលអនុប្បទាននូវភោគៈ ដោយភ្ជាប់ជាមួយនឹង*ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ* ពីភោគីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក៏ត្រូវចាត់ទុកជាកម្មសិទ្ធិករ ចំពោះការអនុវត្តសិទ្ធិទាមទារ ដោយផ្អែកលើសិទ្ធិប្រត្យក្សដែរ។ | ១- ភោគីដែលប្រើប្រាស់ និងអាស្រ័យផលជាបន្តនូវអចលនវត្ថុដែលបានទទួលប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី តែមិនទាន់ចុះបញ្ជីអចលនវត្ថុដែលជាការចាំបាច់ដើម្បីទទួលកម្មសិទ្ធិពេញលេញ ដោយសារមិនទាន់បានរៀបចំប្រព័ន្ធប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីទេ ត្រូវចាត់ទុកថាជាកម្មសិទ្ធិករ ចំពោះការអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស។<br><br>២-..........<br><br>៣- អ្នកដែលបានទទួលអនុប្បទាននូវភោគៈ ដោយភ្ជាប់ជាមួយនឹងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ពីភោគីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក៏ត្រូវចាត់ទុកជាកម្មសិទ្ធិករ ចំពោះការអនុវត្តសិទ្ធិទាមទារ ដោយផ្អែកលើសិទ្ធិប្រត្យក្សដែរ។ |

| | |
|---|---|
| **មាត្រា ២៩១ ករណីយកិច្ចរបស់ម្ចាស់សេវភាព (កថាខណ្ឌទី ៤)**<br><br>១~៣-..........<br><br>៤- ការទាមទារឲ្យរំលត់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ មិនរារាំងក្នុងការទាមទារសំណងនៃការខូចខាត ដោយផ្អែកលើអំពើអត្យានុកូល ចំពោះ*ផលុបភោគី*ឡើយ។<br><br>៥-.......... | **មាត្រា ២៩១ ករណីយកិច្ចរបស់ម្ចាស់សេវភាព (កថាខណ្ឌទី ៤)**<br><br>១~៣-..........<br><br>៤- ការទាមទារឲ្យរំលត់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ មិនរារាំងក្នុងការទាមទារសំណងនៃការខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូល ចំពោះម្ចាស់សេវភាពឡើយ។<br><br>៥-.......... |
| **មាត្រា ៣៤៩ ការរំលោភបំពានលើស្ថានភាព (កថាខណ្ឌទី ១)**<br><br>១- នៅពេលធ្វើកិច្ចសន្យា *បើភាគីម្ខាងនៃកិច្ចសន្យា បានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ* ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។<br><br>២-.......... | **មាត្រា ៣៤៩ ការរំលោភបំពានលើស្ថានភាព (កថាខណ្ឌទី ១)**<br><br>១- នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើដោយមិនត្រឹមត្រូវនូវឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀតខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។<br><br>២-.......... |
| **មាត្រា ៣៨៥ សិទ្ធិរបស់ម្ចាស់បំណុលក្នុងការទាមទារឲ្យអនុវត្តកាតព្វកិច្ច (កថាខណ្ឌទី១)**<br><br>១- ម្ចាស់បំណុលអាចទាមទារឲ្យកូនបំណុលអនុវត្តកាតព្វកិច្ច*តាមផ្លូវតុលាការ*។<br><br>២-.......... | **មាត្រា ៣៨៥ សិទ្ធិរបស់ម្ចាស់បំណុលក្នុងការទាមទារឲ្យអនុវត្តកាតព្វកិច្ច (កថាខណ្ឌទី១)**<br><br>១- ម្ចាស់បំណុលអាចទាមទារឲ្យកូនបំណុលអនុវត្តកាតព្វកិច្ចក្រៅផ្លូវការ ឬ *តាមផ្លូវតុលាការ*។<br><br>២-.......... |
| **មាត្រា ៣៩៣ ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ**<br><br>*ការមិនអនុវត្តកាតព្វកិច្ច* សំដៅទៅលើករណីដែលកូនបំណុលបានអនុវត្តកាតព្វកិច្ច តែការផ្ដល់តាវកាលិកមិនពេញលេញ ឬ ករណីដែលបានអនុវត្តតែមួយផ្នែកនៃកាតព្វកិច្ច ឬ ករណីផ្សេងទៀតដែលគ្មានការអនុវត្តឲ្យបានពេញលេញតាមខ្លឹមសារនៃកាតព្វកិច្ច។ | **មាត្រា ៣៩៣ ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ**<br><br>ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ សំដៅទៅលើករណីដែលកូនបំណុលបានអនុវត្តកាតព្វកិច្ច តែការផ្ដល់តាវកាលិកមិនពេញលេញ ឬ ករណីដែលបានអនុវត្តតែមួយផ្នែកនៃកាតព្វកិច្ច ឬ ករណីផ្សេងទៀតដែលគ្មានការអនុវត្តឲ្យបានពេញលេញតាមខ្លឹមសារនៃកាតព្វកិច្ច។ |

| | |
|---|---|
| **មាត្រា ៤១២ សិទ្ធិរំលាយក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬបាត់បង់ (កថាខណ្ឌទី២)**<br><br>១-..........<br><br>២- *ក្នុងករណីដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ* បើភាគីបានអនុវត្តសិទ្ធិរំលាយ ភាគីនោះត្រូវសងជាទឹកប្រាក់នូវតម្លៃនៃវត្ថុដែលជាកម្មវត្ថុនោះ ត្រឹមកម្រិតតម្លៃដែលបានកំណត់ក្នុងកិច្ចសន្យា។<br><br>៣-.......... | **មាត្រា ៤១២ សិទ្ធិរំលាយក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬបាត់បង់ (កថាខណ្ឌទី២)**<br><br>១-..........<br><br>២- បើភាគីបានអនុវត្តសិទ្ធិរំលាយ ភាគីនោះត្រូវសងជាទឹកប្រាក់នូវតម្លៃនៃវត្ថុដែលជាកម្មវត្ថុនោះ ត្រឹមកម្រិតតម្លៃដែលបានកំណត់ក្នុងកិច្ចសន្យា។<br><br>៣-.......... |
| **មាត្រា ៤២០ ការទទួលបន្ទុកហានិភ័យចំពោះកិច្ចសន្យាអញ្ញមញ្ញដែលមានអត្ថន័យត្រូវធ្វើ ឬ មិនត្រូវធ្វើ (វាក្យខណ្ឌទី ២)**<br><br>ចំពោះកិច្ចសន្យាអញ្ញមញ្ញដែលមានអត្ថន័យឲ្យភាគីម្ខាងត្រូវធ្វើ ឬ មិនត្រូវធ្វើ ក្នុងករណីដែលការអនុវត្តកាតព្វកិច្ចនោះ ក្លាយជាអលទ្ធភាព ដោយគ្មានកំហុសរបស់ភាគីទាំងសងខាងទេ កាតព្វកិច្ចនោះត្រូវរលត់។ *ប៉ុន្តែ* កូនបំណុលមិនអាចទាមទារតាវកាលិកតបពីម្ចាស់បំណុលបានទេ។ | **មាត្រា ៤២០ ការទទួលបន្ទុកហានិភ័យចំពោះកិច្ចសន្យាអញ្ញមញ្ញដែលមានអត្ថន័យត្រូវធ្វើ ឬ មិនត្រូវធ្វើ (វាក្យខណ្ឌទី ២)**<br><br>ចំពោះកិច្ចសន្យាអញ្ញមញ្ញដែលមានអត្ថន័យឲ្យភាគីម្ខាងត្រូវធ្វើឬ មិនត្រូវធ្វើ ក្នុងករណីដែលការអនុវត្តកាតព្វកិច្ចនោះ ក្លាយជាអលទ្ធភាព ដោយគ្មានកំហុសរបស់ភាគីទាំងសងខាងទេ កាតព្វកិច្ចនោះត្រូវរលត់។ ក្នុងករណីនេះ កូនបំណុលមិនអាចទាមទារតាវកាលិកតបពីម្ចាស់បំណុលបានទេ។ |
| **មាត្រា៤២៨ ល័ក្ខខ័ណ្ឌនៃការលុបចោលនូវអំពើដែលនាំឲ្យខូចប្រយោជន៍ (កថាខណ្ឌទី១)**<br><br>១-ម្ចាស់បំណុលអាចលុបចោលនូវអំពើដែលកូនបំណុលបានធ្វើ ដោយដឹងថា អំពើនោះធ្វើឲ្យខូចខាតផលប្រយោជន៍ដល់*សិទ្ធិលើបំណុលនោះ* ហើយទាមទារឲ្យ*អ្នកដែលបានទទួលផលប្រយោជន៍ពីអំពើរបស់កូនបំណុលនោះ* សងមកវិញនូវវត្ថុដែលអ្នកនោះ បានទទួលជាតាវកាលិក ឬ ទឹកប្រាក់ដែលជាតម្លៃនៃវត្ថុនោះ តាមផ្លូវតុលាការបាន។<br><br>២~៣-.......... | **មាត្រា៤២៨ ល័ក្ខខ័ណ្ឌនៃការលុបចោលនូវអំពើដែលនាំឲ្យខូចប្រយោជន៍ (កថាខណ្ឌទី១)**<br><br>១- ម្ចាស់បំណុលអាចលុបចោលនូវអំពើដែលកូនបំណុលបានធ្វើ ដោយដឹងថា អំពើនោះធ្វើឲ្យខូចខាតផលប្រយោជន៍ដល់ម្ចាស់បំណុល ហើយទាមទារឲ្យអ្នកដែលបានទទួលផលប្រយោជន៍ពីអំពើរបស់កូនបំណុលនោះ ឬ អ្នកដែលបានទទួលបន្ទុកបន្តវត្ថុពីអ្នកនោះ សងមកវិញនូវវត្ថុដែលអ្នកនោះ បានទទួលជាតាវកាលិក ឬ ទឹកប្រាក់ដែលជាតម្លៃនៃវត្ថុនោះ តាមផ្លូវតុលាការបាន។<br><br>២~៣-.......... |
| **មាត្រា ៤២៩ សិទ្ធិដែលត្រូវបានរក្សាការពារ (វាក្យខណ្ឌទី ២)**<br><br>បញ្ញត្តិនៃមាត្រា ៤២៨ (ល័ក្ខខ័ណ្ឌនៃការលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍) ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលក្រៅពីសិទ្ធិលើបំណុល | **មាត្រា ៤២៩ សិទ្ធិដែលត្រូវបានរក្សាការពារ (វាក្យខណ្ឌទី ២)**<br><br>បញ្ញត្តិនៃមាត្រា ៤២៨ (ល័ក្ខខ័ណ្ឌនៃការលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍) ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលក្រៅពីសិទ្ធិលើ |

| | |
|---|---|
| ដែលមានគោលបំណងសងជាប្រាក់ ។ ប៉ុន្តែនៅ*ពេលដែលការទាញហេតុផលដោយផ្ទាល់មាត់* ដែលទាក់ទងនឹងសាលក្រម ឬ សាលដីកាដែលលុបចោលអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍ សិទ្ធិលើបំណុលនោះ ត្រូវប្តូរទៅជាសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់វិញ។ | បំណុលដែលមានគោលបំណងសងជាប្រាក់ ។ ប៉ុន្តែនៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ដែលទាក់ទងនឹងសាលក្រម ឬ សាលដីកាដែលលុបចោលអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍ សិទ្ធិលើបំណុលនេះ ត្រូវប្តូរទៅជាសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់វិញ។ |
| **មាត្រា ៤៥៧ ការតម្កល់ (វាក្យខណ្ឌទី ១ កថាខណ្ឌទី២)**<br>១-..........<br>ក~ខ-..........<br>២- *នៅពេលដែលម្ចាស់បំណុលមិនព្រមទទួលការតម្កល់ ឬ សាលក្រម ឬ សាលដីកាដែលប្រកាសថាការតម្កល់នោះ មានសុពលភាពមិនទាន់ចូលជាស្ថាពរទេ* អ្នកសងអាចយកវត្ថុតម្កល់មកវិញបាន។ ក្នុងករណីនេះ អ្នកសងត្រូវបានចាត់ទុកថា មិនបានធ្វើការតម្កល់។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសិទ្ធិលើការបញ្ចាំ ឬ  សិទ្ធិលើហ៊ីប៉ូតែក ត្រូវបានរលត់ដោយការតម្កល់នោះ។<br>៣-.......... | **មាត្រា ៤៥៧ ការតម្កល់ (វាក្យខណ្ឌទី ១ កថាខណ្ឌទី២)**<br>១-..........<br>ក~ខ-..........<br>២- នៅក្នុងអំឡុងពេលដែលម្ចាស់បំណុលមិនទាន់ព្រមចំពោះការតម្កល់ ឬ ក្នុងអំឡុងពេលដែលសាលក្រម ឬ សាលដីកាដែលប្រកាសថាការតម្កល់នោះ មានសុពលភាពមិនទាន់ចូលជាស្ថាពរទេ អ្នកសងអាចយកវត្ថុតម្កល់មកវិញបាន។ ក្នុងករណីនេះ អ្នកសងត្រូវបានចាត់ទុកថា មិនបានធ្វើការតម្កល់។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសិទ្ធិលើការបញ្ចាំ ឬ  សិទ្ធិលើហ៊ីប៉ូតែក ត្រូវបានរលត់ដោយការតម្កល់នោះ ។<br>៣-.......... |
| **មាត្រា ៥០៥ អានុភាពនៃការជូនដំណឹង និងការយល់ព្រម (វាក្យខណ្ឌទី១ កថាខណ្ឌទី១)**<br>១- ប្រសិនបើកូនបំណុលធ្វើការយល់ព្រមដែលបានកំណត់នៅក្នុងមាត្រា ៥០៣ (ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) នៃក្រមនេះ ដោយគ្មានការតវ៉ា ទោះបីជាខ្លួនមានហេតុដែលអាចតតាំងចំពោះអនុប្បទាយីក៏ដោយ ក៏កូនបំណុល*មិនអាចយកហេតុនោះតតាំងចំពោះអនុប្បទាយីបានឡើយ* ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវរាំងក្នុងការយកវត្ថុវិញ បើកូនបំណុលប្រគល់វត្ថុណាឲ្យអនុប្បទាយីដើម្បីរំលត់កាតព្វកិច្ចរបស់ខ្លួន ឬ ក្នុងការចាត់ទុកថា កាតព្វកិច្ចមិនកើតឡើង បើកូនបំណុលទទួលបន្ទុកនូវកាតព្វកិច្ចចំពោះអនុប្បទាយី ដើម្បីរំលត់កាតព្វកិច្ចរបស់ខ្លួន។<br>២-.......... | **មាត្រា ៥០៥ អានុភាពនៃការជូនដំណឹង និងការយល់ព្រម (វាក្យខណ្ឌទី១ កថាខណ្ឌទី១)**<br>១- ប្រសិនបើកូនបំណុលការយល់ព្រមដែលបានកំណត់នៅក្នុងមាត្រា ៥០៣ (ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) នៃក្រមនេះដោយគ្មានការតវ៉ា ទោះបីជាខ្លួនមានហេតុដែលអាចតតាំងចំពោះអនុប្បទាយីក៏ដោយ ក៏កូនបំណុលមិនអាចយកហេតុនោះ តតាំងចំពោះអនុប្បទានិកបានឡើយ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវរាំងក្នុងការយកវត្ថុវិញ បើកូនបំណុលប្រគល់វត្ថុណាឲ្យអនុប្បទាយីដើម្បីរំលត់កាតព្វកិច្ចរបស់ខ្លួន ឬ ក្នុងការចាត់ទុកថា កាតព្វកិច្ចមិនកើតឡើង បើកូនបំណុលទទួលបន្ទុកនូវកាតព្វកិច្ចចំពោះអនុប្បទាយី ដើម្បីរំលត់កាតព្វកិច្ចរបស់ខ្លួន។<br>២-.......... |

| | |
|---|---|
| **មាត្រា ៥២៨ ការផ្ទេរកម្មសិទ្ធិ (កថាខណ្ឌទី១)**<br>១- ចំពោះការផ្ទេរកម្មសិទ្ធិលើកម្មវត្ថុក្នុងកិច្ចសន្យាលក់ទិញ ត្រូវអនុវត្តទៅតាមគោលការណ៍ទូទៅដែលបានកំណត់*នៅក្នុងមាត្រា ១៣៣ (ការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្ស ដោយការព្រមព្រៀង) មាត្រា ១៣៤ (ល័ក្ខខ័ណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្ស) មាត្រា ១៣៥ (ល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង) មាត្រា ១៦០ (លទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ) និង មាត្រា ១៨៧ (លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ)* នៃក្រមនេះ។<br>២-.......... | **មាត្រា ៥២៨ ការផ្ទេរកម្មសិទ្ធិ (កថាខណ្ឌទី១)**<br>១- ចំពោះការផ្ទេរកម្មសិទ្ធិលើកម្មវត្ថុក្នុងកិច្ចសន្យាលក់ទិញ ត្រូវអនុវត្តទៅតាមគោលការណ៍ទូទៅដែលបានកំណត់ចាប់ពីមាត្រា ១៣៣ (ការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្សដោយការព្រមព្រៀង) ដល់មាត្រា ១៣៥ (ល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង) នៃក្រមនេះ។<br>២-.......... |
| **មាត្រា ៥៣៤ ការទទួលខុសត្រូវក្នុងការធានាក្នុងករណីដែលមានសិទ្ធិប្រត្យក្សជាផលុបភោគ (កថាខណ្ឌទី១)**<br>១- ក្នុងករណីដែលកម្មវត្ថុនៃការលក់ទិញភ្ជាប់ជាមួយ*សិទ្ធិជួលជាអចិន្ត្រៃយ៍*ផលុបភោគ *សិទ្ធិប្រើប្រាស់* សេវភាព សិទ្ធិជួល សិទ្ធិឃាត់ទុក ឬ សិទ្ធិលើការបញ្ចាំ សម្រាប់តតិយជន ហើយបើអ្នកទិញមិនអាចប្រើប្រាស់ ឬ ទទួលផលពីកម្មវត្ថុទាំងមូល ឬ មួយផ្នែក ដោយសារអត្ថិភាពនៃសិទ្ធិនោះ អ្នកទិញដែលមិនបានដឹងអំពីអត្ថិភាពនៃសិទ្ធិនោះ នៅពេលធ្វើកិច្ចសន្យា អាចទាមទារសំណងនៃការខូចខាតពីអ្នកលក់បាន។<br>២~៤-.......... | **មាត្រា ៥៣៤ ការទទួលខុសត្រូវក្នុងការធានាក្នុងករណីដែលមានសិទ្ធិប្រត្យក្សជាផលុបភោគជាអាទិ៍ (កថាខណ្ឌទី១)**<br>១- ក្នុងករណីដែលកម្មវត្ថុនៃការលក់ទិញភ្ជាប់ជាមួយសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យនៅ សេវភាព សិទ្ធិជួល សិទ្ធិឃាត់ទុក ឬ សិទ្ធិលើការបញ្ចាំ សម្រាប់តតិយជន ហើយបើអ្នកទិញមិនអាចប្រើប្រាស់ ឬ ទទួលផលពីកម្មវត្ថុទាំងមូល ឬ មួយផ្នែក ដោយសារអត្ថិភាពនៃសិទ្ធិនោះ អ្នកទិញដែលមិនបានដឹងអំពីអត្ថិភាពនៃសិទ្ធិនោះ នៅពេលធ្វើកិច្ចសន្យា អាចទាមទារសំណងនៃការខូចខាតពីអ្នកលក់បាន។<br>២~៤-.......... |
| **មាត្រា ៥៣៩ ករណីយកិច្ចផ្តល់វត្ថុដែលគ្មានវិការៈ (ចំណុចគ កថាខណ្ឌទី២)**<br>១-..........<br>២-..........<br>ក~ខ-..........<br>គ- វត្ថុនោះមិនស្របនឹងវិធីប្រើដែល*អ្នកទិញត្រូវបានបង្ហាញ* ដោយជាក់លាក់ ឬ ដោយតុណ្ហីភាព នៅពេលធ្វើកិច្ចសន្យា។<br>ឃ~ង-.......... | **មាត្រា ៥៣៩ ករណីយកិច្ចផ្តល់វត្ថុដែលគ្មានវិការៈ (ចំណុចគ កថាខណ្ឌទី២)**<br>១-..........<br>២-..........<br>ក~ខ-..........<br>គ- វត្ថុនោះមិនស្របនឹងវិធីប្រើដែលអ្នកលក់ត្រូវបានបង្ហាញ ដោយជាក់លាក់ ឬ ដោយតុណ្ហីភាព នៅពេលធ្វើកិច្ចសន្យា។<br>ឃ~ង-.......... |

| | |
|---|---|
| **មាត្រា ៥៧៨ និយមន័យនៃការខ្ចីបរិភោគ**<br><br>ការខ្ចីបរិភោគ សំដៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ហៅថាអ្នកឲ្យខ្ចី មានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ *ស្បៀងអាហារ* ឬ វត្ថុជំនួសផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់ ឲ្យទៅភាគីម្ខាងទៀត ហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឲ្យអ្នកឲ្យខ្ចីវិញ នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឲ្យខ្ចីនោះ។ | **មាត្រា ៥៧៨ និយមន័យនៃការខ្ចីបរិភោគ**<br><br>ការខ្ចីបរិភោគ សំដៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ហៅថាអ្នកឲ្យខ្ចី មានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ ស្បៀងអាហារ ស្រូវ ឬ វត្ថុជំនួសផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់ ឲ្យទៅភាគីម្ខាងទៀត ហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឲ្យអ្នកឲ្យខ្ចីវិញ នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឲ្យខ្ចីនោះ។ |
| **មាត្រា ៦០៥ ការទទួលខុសត្រូវរបស់ភតិបតី ចំពោះវិការៈនៃវត្ថុជួល (កថាខណ្ឌទី៤)**<br><br>១~៣-..........<br><br>៤- ជំនួសនឹង*ការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ* ភតិកៈអាចទាមទារឲ្យបន្ថយថ្លៃឈ្នួលដែលសមរម្យនឹងវិការៈបាន ដោយគិតតាំងពីពេលដែលបានប្រគល់។<br><br>៥~៦-.......... | **មាត្រា ៦០៥ ការទទួលខុសត្រូវរបស់ភតិបតី ចំពោះវិការៈនៃវត្ថុជួល (កថាខណ្ឌទី៤)**<br><br>១~៣-..........<br><br>៤- ជំនួសនឹងការទាមទារដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ភតិកៈអាចទាមទារឲ្យបន្ថយថ្លៃឈ្នួលដែលសមរម្យនឹងវិការៈបាន ដោយគិតតាំងពីពេលដែលបានប្រគល់។<br><br>៥~៦-.......... |
| **មាត្រា ៧៤៨ អំពើអនីត្យានុកូលរបស់នីតិបុគ្គល (កថាខណ្ឌទី១)**<br><br>១- នីតិបុគ្គលត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាត ដែល *សមាជិកគណៈកម្មការនាយក* ឬ អ្នកតំណាងឯទៀត បានបង្កដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ច ។<br><br>២-.......... | **មាត្រា ៧៤៨ អំពើអនីត្យានុកូលរបស់នីតិបុគ្គល (កថាខណ្ឌទី១)**<br><br>១- នីតិបុគ្គលត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាត ដែល អភិបាល ឬ អ្នកតំណាងឯទៀត បានបង្កដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ច ។<br><br>២-.......... |
| **មាត្រា ៧៦៣ ការទូទាត់ប្រាក់ចំណេញ និង ខាត**<br><br>ប្រសិនបើជនរងគ្រោះបានទទួលផលចំណេញដោយសារអំពើអនីត្យានុកូល ចំនួនប្រាក់ចំណេញនោះត្រូវដកចេញ នៅពេលធ្វើការគណនា*ចំនួនទឹកប្រាក់នៃការខូចខាត*។ | **មាត្រា ៧៦៣ ការទូទាត់ប្រាក់ចំណេញ និង ខាត**<br><br>ប្រសិនបើជនរងគ្រោះបានទទួលផលចំណេញដោយសារអំពើអនីត្យានុកូល នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃសំណងការខូចខាត។ |

| | |
|---|---|
| **មាត្រា ៧៦៤ ការទូទាត់នូវកំហុស**<br><br>បើកំហុសរបស់ជនរងគ្រោះ ឬ កំហុសរបស់អ្នកដែលមានករណីយកិច្ចត្រូវត្រួតពិនិត្យជនរងគ្រោះ បានរួមចំណែកក្នុងការកើតឡើង ឬ រីករាលដាលនៃការខូចខាត តុលាការអាចគិតពិចារណានូវកម្រិតនៃការរួមចំណែកនោះ នៅពេលធ្វើការគណនា*ចំនួនទឹកប្រាក់នៃការខូចខាត*។ | **មាត្រា ៧៦៤ ការទូទាត់នូវកំហុស**<br><br>បើកំហុសរបស់ជនរងគ្រោះ ឬ កំហុសរបស់អ្នកដែលមានករណីយកិច្ចត្រូវត្រួតពិនិត្យជនរងគ្រោះ បានរួមចំណែកក្នុងការកើតឡើង ឬ រីករាលដាលនៃការខូចខាត តុលាការអាចគិតពិចារណានូវកម្រិតនៃការរួមចំណែកនោះ នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃសំណងការខូចខាត។ |
| **មាត្រា ៧៧០ ភាពទៅជាមួយគ្នានៃសិទ្ធិប្រាតិភោគប្រត្យក្ស (កថាខណ្ឌទី២)**<br><br>១-..........<br><br>២- បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានា *ដោយសិទ្ធិលើការបញ្ចាំដើម្បីធានាបំណុលអណ្តែត ឬ* ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត។ | **មាត្រា ៧៧០ ភាពទៅជាមួយគ្នានៃសិទ្ធិប្រាតិភោគប្រត្យក្ស (កថាខណ្ឌទី២)**<br><br>១-..........<br><br>២- បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានា ដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត។ |
| **មាត្រា ៧៨៦ ឯកសិទ្ធិចំពោះសោហ៊ុយសម្រាប់បុណ្យសព (កថាខណ្ឌទី២**<br><br>១-..........<br><br>២- ក្នុងករណីដែលញាតិរបស់កូនបំណុលដែលមាន*អាហារកិច្ច* បានទទួលមរណភាព ឯកសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក៏មានអត្ថិភាពចំពោះសោហ៊ុយសម្រាប់បុណ្យសពដែលកូនបំណុលបានធ្វើឡើង ទៅតាមឋានៈរបស់ញាតិនោះដែរ។ | **មាត្រា ៧៨៦ ឯកសិទ្ធិចំពោះសោហ៊ុយសម្រាប់បុណ្យសព (កថាខណ្ឌទី២**<br><br>១-..........<br><br>២- ក្នុងករណីដែលញាតិរបស់កូនបំណុលដែលមានអាហារកាតព្វកិច្ច បានទទួលមរណភាព ឯកសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក៏មានអត្ថិភាពចំពោះសោហ៊ុយសម្រាប់បុណ្យសពដែលកូនបំណុលបានធ្វើឡើង ទៅតាមឋានៈរបស់ញាតិនោះដែរ។ |
| **មាត្រា ៧៨៧ ឯកសិទ្ធិចំពោះការផ្តល់នូវវត្ថុសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ**<br><br>ឯកសិទ្ធិចំពោះការផ្តល់នូវវត្ថុប្រើប្រាស់ប្រចាំថ្ងៃ មានអត្ថិភាពចំពោះការផ្តល់ចំណីអាហារ និង វត្ថុប្រើប្រាស់ផ្សេងៗរៀងរាល់ថ្ងៃ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែចុងក្រោយដែលចាំបាច់សម្រាប់ជីវភាពរបស់ | **មាត្រា ៧៨៧ ឯកសិទ្ធិចំពោះការផ្តល់នូវវត្ថុសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ**<br><br>ឯកសិទ្ធិចំពោះការផ្តល់នូវវត្ថុប្រើប្រាស់ប្រចាំថ្ងៃ មានអត្ថិភាពចំពោះការផ្តល់ចំណីអាហារ និង វត្ថុប្រើប្រាស់ផ្សេងៗរៀងរាល់ថ្ងៃ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែចុងក្រោយដែលចាំបាច់សម្រាប់ |

| | |
|---|---|
| កូនបំណុល ឬ ញាតិដែលរស់នៅជាមួយកូនបំណុលហើយដែលកូនបំណុលនោះមាន*អាហារកិច្ច* និង អ្នកបម្រើ ។ | ជីវភាពរបស់កូនបំណុល ឬ ញាតិដែលរស់នៅជាមួយកូនបំណុលហើយដែលកូនបំណុលនោះមានអាហារកាតព្វកិច្ច និង អ្នកបម្រើ ។ |
| **មាត្រា ៧៩១ ទំហំនៃវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិចំពោះការជួលអចលនវត្ថុ ក្នុងករណីអនុប្បទាននូវសិទ្ធិជួល ឬ ជួលបន្ត (វាក្យខណ្ឌទី២)**<br>ក្នុងករណីអនុប្បទាននូវសិទ្ធិជួល ឬ ជួលបន្ត ឯកសិទ្ធិរបស់ភតិបតីមានអានុភាពលើចលនវត្ថុរបស់អនុប្បទានិក ឬ ភតិកៈបន្ត ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ *ចំពោះប្រាក់ដែលអនុប្បទានិក ឬ ភតិកៈបន្តនោះទទួល*។ | **មាត្រា ៧៩១ ទំហំនៃវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិចំពោះការជួលអចលនវត្ថុ ក្នុងករណីអនុប្បទាននូវសិទ្ធិជួល ឬ ជួលបន្ត (វាក្យខណ្ឌទី២)**<br>ក្នុងករណីអនុប្បទាននូវសិទ្ធិជួល ឬ ជួលបន្ត ឯកសិទ្ធិរបស់ភតិបតីមានអានុភាពលើចលនវត្ថុរបស់អនុប្បទានិក ឬ ភតិកៈបន្ត ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះប្រាក់ដែលអនុប្បទាយី ឬ ភតិបតីបន្តទទួល ។ |
| **មាត្រា ៨៦១ អនុប្បទាន ឬ ការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក (វាក្យខណ្ឌទី១ កថាខណ្ឌទី១)**<br>១- ម្ចាស់បំណុលហ៊ីប៉ូតែក អាចធ្វើអនុប្បទាន ឬ បោះបង់លំដាប់នៃហ៊ីប៉ូតែកបាន *ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលផ្សេងទៀត* ចំពោះកូនបំណុលតែម្នាក់។ ម្ចាស់បំណុលហ៊ីប៉ូតែក ក៏អាចផ្លាស់ប្តូរលំដាប់នៃហ៊ីប៉ូតែកនោះបាន ដោយការព្រមព្រៀងជាមួយម្ចាស់បំណុលហ៊ីប៉ូតែកផ្សេងទៀត។ ប៉ុន្តែ បើមានបុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ចំពោះការផ្លាស់ប្តូរនោះ ម្ចាស់បំណុលហ៊ីប៉ូតែកត្រូវទទួលការយល់ព្រមអំពីបុគ្គលនោះ ។<br>២~៤-.......... | **មាត្រា ៨៦១ អនុប្បទាន ឬ ការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក (វាក្យខណ្ឌទី១ កថាខណ្ឌទី១)**<br>១- ម្ចាស់បំណុលហ៊ីប៉ូតែក អាចធ្វើអនុប្បទាន ឬ បោះបង់លំដាប់នៃហ៊ីប៉ូតែកបាន ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលហ៊ីប៉ូតែកផ្សេងទៀតចំពោះកូនបំណុលតែម្នាក់ ។ ម្ចាស់បំណុលហ៊ីប៉ូតែក ក៏អាចផ្លាស់ប្តូរលំដាប់នៃហ៊ីប៉ូតែកនោះបាន ដោយការព្រមព្រៀងជាមួយម្ចាស់បំណុលហ៊ីប៉ូតែកផ្សេងទៀត។ ប៉ុន្តែ បើមានបុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ចំពោះការផ្លាស់ប្តូរនោះ ម្ចាស់បំណុលហ៊ីប៉ូតែកត្រូវទទួលការយល់ព្រមអំពីបុគ្គលនោះ ។<br>២~៤-.......... |
| **មាត្រា ៩០៣ ទំហំនៃកាតព្វកិច្ចធានា(កថាខណ្ឌទី១)**<br>១- កាតព្វកិច្ចធានាត្រូវរាប់*បញ្ចូល* ទាំងការប្រាក់ ប្រាក់ជានាសំណងក្នុងករណីបំពានកិច្ចសន្យា និង សំណងការខូចខាត ដែលទាក់ទងនឹងកាតព្វកិច្ចចម្បង និង អ្វីដែលកើតឡើងបន្ទាប់បន្សំ ពីកាតព្វកិច្ចចម្បងនោះ។<br>២-.......... | **មាត្រា ៩០៣ ទំហំនៃកាតព្វកិច្ចធានា(កថាខណ្ឌទី១)**<br>១- កាតព្វកិច្ចធានាត្រូវរាប់បញ្ចូល ទាំងការប្រាក់ ប្រាក់ជានាសំណងក្នុងករណីបំពានកិច្ចសន្យា និង សំណងការខូចខាត ដែលទាក់ទងនឹងកាតព្វកិច្ចចម្បង និង អ្វីដែលកើតឡើងបន្ទាប់បន្សំ ពីកាតព្វកិច្ចចម្បងនោះ។<br>២-.......... |
| **មាត្រា ៩២២ ការបង្កើតកាតព្វកិច្ចដោយសាមគ្គីភាព (កថាខណ្ឌទី៣)**<br>១~២-.......... | **មាត្រា ៩២២ ការបង្កើតកាតព្វកិច្ចដោយសាមគ្គីភាព (កថាខណ្ឌទី៣)**<br>១~២-.......... |

| | |
|---|---|
| ៣- ម្ចាស់បំណុលអាចលើកលែងសាមគ្គីភាព ចំពោះកូនបំណុលណាមួយ *ដោយមិនចាំបាច់មានការយល់ព្រមពីកូនបំណុលផ្សេងទៀត* បាន។<br><br>៤~៥-.......... | ៣- ម្ចាស់បំណុលអាចលើកលែងសាមគ្គីភាព ចំពោះកូនបំណុលណាមួយបាន។<br><br>៤~៥-.......... |
| **មាត្រា ៩៣២ សិទ្ធិទាមទារសំណងរបស់កូនបំណុលដែលបានសង (វាក្យខណ្ឌទី២ កថាខណ្ឌទី១)**<br><br>១- ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ បានរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ បានចេញចំណាយផ្សេងទៀតរបស់ខ្លួន ហើយធ្វើឲ្យកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀតរួចផុតពីកាតព្វកិច្ច កូនបំណុលនោះត្រូវទទួលសិទ្ធិទាមទារសំណងពីកូនបំណុលផ្សេងទៀតចំពោះបន្ទុករៀងៗខ្លួន ។ ក្នុងករណីដែលការសង ឬ ចំណាយផ្សេងទៀតរបស់កូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ មានចំពោះតែកាតព្វកិច្ចមួយភាគ ហើយកូនបំណុលនោះ និងកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀត បានទទួលការរួចផុតពីកាតព្វកិច្ច តាមកម្រិតនៃភាគនោះ កូនបំណុលនោះអាចទាមទារសំណង *តាមសមាមាត្រនៃបន្ទុករបស់កូនបំណុលផ្សេងទៀត* បាន ។<br><br>២-.......... | **មាត្រា ៩៣២ សិទ្ធិទាមទារសំណងរបស់កូនបំណុលដែលបានសង (វាក្យខណ្ឌទី២ កថាខណ្ឌទី១)**<br><br>១- ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ បានរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ បានចេញចំណាយផ្សេងទៀតរបស់ខ្លួន ហើយធ្វើឲ្យកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀតរួចផុតពីកាតព្វកិច្ច កូនបំណុលនោះត្រូវទទួលសិទ្ធិទាមទារសំណងពីកូនបំណុលផ្សេងទៀត ចំពោះបន្ទុករៀងៗខ្លួន ។ ក្នុងករណីដែលការសង ឬ ចំណាយផ្សេងទៀតរបស់កូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ មានចំពោះតែកាតព្វកិច្ចមួយភាគ ហើយកូនបំណុលនោះ និងកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀត បានទទួលការរួចផុតពីកាតព្វកិច្ច តាមកម្រិតនៃភាគនោះ កូនបំណុលនោះអាចទាមទារសំណង តាមសមាមាត្រនឹងចំនួនភាគរយនៃចំនួនទឹកប្រាក់សរុបនៃកាតព្វកិច្ចបាន ។<br><br>២-.......... |
| **មាត្រា ៩៤២ ការរលត់ញាតិភាព ដោយការកាត់កាល់ *ឬ លែងទទួលស្គាល់* (ចំណងជើង និងបញ្ញត្តិនៃមាត្រានេះ)**<br><br>ញាតិភាពរវាងកូនចិញ្ចឹម សហព័ទ្ធរបស់ជននោះ បច្ឆាញាតិផ្ទាល់ និង សហព័ទ្ធរបស់បច្ឆាញាតិផ្ទាល់នោះ ជាមួយនឹងឪពុកម្តាយចិញ្ចឹម និង ញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមនោះ ត្រូវបានបញ្ចប់ដោយការកាត់កាល់ *ឬ លែងទទួលស្គាល់* ។ | **មាត្រា ៩៤២ ការរលត់ញាតិភាព ដោយការកាត់កាល់ (ចំណងជើង និងបញ្ញត្តិនៃមាត្រានេះ)**<br><br>ញាតិភាពរវាងកូនចិញ្ចឹម សហព័ទ្ធរបស់ជននោះ បច្ឆាញាតិផ្ទាល់ និង សហព័ទ្ធរបស់បច្ឆាញាតិផ្ទាល់នោះ ជាមួយនឹងឪពុកម្តាយចិញ្ចឹម និង ញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមនោះ ត្រូវបានបញ្ចប់ដោយការកាត់កាល់ ។ |
| **មាត្រា ៩៧៥ ការទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ច (ចំណុច ខ)**<br><br>ក-.......... | **មាត្រា ៩៧៥ ការទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ច (ចំណុច ខ)**<br><br>ក-.......... |

| | |
|---|---|
| ខ- កាតព្វកិច្ច និង ករណីយកិច្ចផ្សេងៗទៀត ដែល*<u>ប្ដី ឬ ប្រពន្ធទាំងសងខាង</u>* បានព្រមព្រៀងតាមលិខិតជាលាយល័ក្ខណ៍អក្សរ ជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ កាតព្វកិច្ច និង ករណីយកិច្ចផ្សេងៗទៀត ដែលប្ដី ឬ ប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរ ពីប្រពន្ធ ឬ ប្ដីម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។<br><br>គ-.......... | ខ- កាតព្វកិច្ច និង ករណីយកិច្ចផ្សេងៗទៀត ដែល<u>ប្ដីប្រពន្ធទាំងសងខាង</u> បានព្រមព្រៀងតាមលិខិតជាលាយល័ក្ខណ៍អក្សរ ជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ កាតព្វកិច្ច និង ករណីយកិច្ចផ្សេងៗទៀត ដែលប្ដី ឬ ប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរ ពីប្រពន្ធ ឬ ប្ដីម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។<br><br>គ-.......... |
| **មាត្រា ៩៧៦ ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ (កថាខណ្ឌទី៣)**<br><br>១~២-..........<br><br>៣- ក្នុងករណីដែលប្ដី ឬ ប្រពន្ធណាម្ខាង បានលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួម ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតផង និង គ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធដែលមិនបានផ្ដល់ការយល់ព្រម អាចទាមទារឲ្យលុបចោលនូវការចាត់ចែងនោះ ទៅតុលាការបាន នៅក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជា*<u>អចលនវត្ថុ</u>* និង នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាទ្រព្យសម្បត្តិផ្សេង។ | **មាត្រា ៩៧៦ ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ (កថាខណ្ឌទី៣)**<br><br>១~២-..........<br><br>៣- ក្នុងករណីដែលប្ដី ឬ ប្រពន្ធណាម្ខាង បានលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួម ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតផង និង គ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធដែលមិនបានផ្ដល់ការយល់ព្រម អាចទាមទារឲ្យលុបចោលនូវការចាត់ចែងនោះ ទៅតុលាការបាន នៅក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជា<u>អចលនវត្ថុសម្រាប់ការអាស្រ័យនៅរបស់គ្រួសារ</u> និង នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាទ្រព្យសម្បត្តិផ្សេង។ |
| **មាត្រា ១០៤២ ករណីយកិច្ចពិភាក្សាអំពីចំណុចសំខាន់ៗទាក់ទងទៅនឹងកូន (ចំណុច ខ)**<br><br>ក-..........<br><br>ខ- ការផ្លាស់ប្ដូរទីសំណាក់របស់កូន ពី*<u>ខេត្ត-ក្រុង</u>*មួយ ទៅ*<u>ខេត្ត-ក្រុង</u>*មួយទៀត ។<br><br>គ~ច-.......... | **មាត្រា ១០៤២ ករណីយកិច្ចពិភាក្សាអំពីចំណុចសំខាន់ៗទាក់ទងទៅនឹងកូន (ចំណុច ខ)**<br><br>ក-..........<br><br>ខ- ការផ្លាស់ប្ដូរទីសំណាក់របស់កូន ពី<u>រាជធានី ខេត្ត</u>មួយ ទៅ<u>រាជធានី ខេត្ត</u>មួយទៀត ។<br><br>គ~ច-.......... |

| | |
|---|---|
| **មាត្រា ១០៧៦ បុគ្គលដែលមិនអាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន**<br>*សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជននៅក្រោមអាណាព្យាបាល* ពុំអាចធ្វើជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានឡើយ។ | **មាត្រា ១០៧៦ បុគ្គលដែលមិនអាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន**<br>សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនពុំអាចធ្វើជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានឡើយ។ |
| **មាត្រា ១១១១ បុគ្គលដែលមិនអាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ**<br>*សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោមអាណាព្យាបាលទូទៅ* ពុំអាចធ្វើជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅបានឡើង។ | **មាត្រា ១១១១ បុគ្គលដែលមិនអាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ**<br>សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អ្នកអាណាព្យាបាលទូទៅពុំអាចធ្វើជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅបានឡើយ។ |
| **មាត្រា ១១៥៧ សន្តតិកម្មជំនួស (វាក្យខណ្ឌទី១ កថាខណ្ឌទី១)**<br>១- បើកូនរបស់មតកជន បានទទួលមរណភាព *នៅមុនពេលចាប់ផ្តើមសន្តតិកម្ម* ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ខាងលើនេះ ឬ ដោយការផ្តាច់មត៌ក កូនរបស់បុគ្គលនោះ ត្រូវក្លាយជាសន្តតិជនជំនួស។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះបុគ្គលដែលមិនមែនជាបច្ចាញាតិផ្ទាល់របស់មតកជន។<br>២-.......... | **មាត្រា ១១៥៧ សន្តតិកម្មជំនួស (វាក្យខណ្ឌទី១ កថាខណ្ឌទី១)**<br>១- បើកូនរបស់មតកជន បានទទួលមរណភាពនៅមុន ឬ ព្រមគ្នានឹងពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ខាងលើនេះ ឬ ដោយការផ្តាច់មត៌ក កូនរបស់បុគ្គលនោះ ត្រូវក្លាយជាសន្តតិជនជំនួស។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះបុគ្គលដែលមិនមែនជាបច្ចាញាតិផ្ទាល់របស់មតកជន។<br>២-.......... |
| **មាត្រា ១២៦១ អានុភាពនៃការបោះបង់ (កថាខណ្ឌទី១)**<br>បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា *បុគ្គលនោះមិនមែនជាសន្តតិជន*តាំងពីដំបូងមក ។ | **មាត្រា ១២៦១ អានុភាពនៃការបោះបង់ (កថាខណ្ឌទី១)**<br>បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជន ចំពោះសន្តតិកម្មនោះ តាំងពីដំបូងមក ។ |
| **មាត្រា ១២៦៦ ការពិភាក្សាបែងចែកមត៌ក (កថាខណ្ឌទី២)**<br>១-.......... | **មាត្រា ១២៦៦ ការពិភាក្សាបែងចែកមត៌ក (កថាខណ្ឌទី២)**<br>១-.......... |

| | |
|---|---|
| ២- ដើម្បីផ្ទេរសិទ្ធិចំពោះវត្ថុតាមការបែងចែកមត៌ក *ការបែងចែកត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅតាមទម្រង់នីមួយៗ ដែលចាំបាច់នៅក្នុងការផ្ទេរសិទ្ធិនោះ។* | ២- ដើម្បីផ្ទេរសិទ្ធិចំពោះវត្ថុតាមការបែងចែកមត៌ក ការបែងចែកត្រូវធ្វើទៅតាមទម្រង់ចាំបាច់ដើម្បីផ្ទេរសិទ្ធិនីមួយៗនោះដូចជាលិខិតជាលាយលក្ខណ៍អក្សរជាអាទិ៍ ។ |

បោះពុម្ពផ្សាយដោយ

ក្រសួងយុត្តិធម៌

ឧបត្ថម្ភដោយ

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ
នៃប្រទេសជប៉ុន (JICA)

ហាមលក់